**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# សេចក្តីណែនាំ
# ស្តីពី
# និយាមនៃការថែទាំអ្នកជំងឺក្នុងព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយនាយកដ្ឋានមន្ទីរពេទ្យនិងគណៈគិលានុបដ្ឋាកកម្ពុជា

ឧបត្ថមថវិកាដោយ

World Health Organization

Cambodia Council of Nurses

Angkor Hospital for Children

២០១៥

# អារម្ភកថា

ការកំណត់តួនាទីនិងភារកិច្ចដល់មន្ត្រីផ្តល់សេវាសុខភាពគ្រប់ប្រភេទ និង គ្រប់លំដាប់ថ្នាក់មានសារៈសំខាន់ជាទីបំផុតដែលជា ការងារមួយ ក្នុង ចំណោម ការងារកំណែ ទម្រង់វិស័យសុខាភិបាលដើម្បីឆ្លើយតបទៅនឹងតម្រូវការបរិបទនិងការវិវត្តនៃស្ថានភាពសុខភាពរបស់ប្រជជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសុខាភិបាលសហការជាមួយអង្គការសុខភាពពិភពលោកនិងក្រុមការងារបច្ចេកទេសមកពីមន្ទីរពេទ្យ និង គ្រឹះស្ថានបណ្តុះបណ្តាលគិលានុបដ្ឋាកនានាបានរៀបចំសេចក្តីណែនាំស្តីពី**និយាមនៃការថែទាំ**ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ អ្នកគ្រប់គ្រងការថែទាំ និង គិលានុបដ្ឋាក-យិកាអនុវត្តការងារថែទាំអ្នកជំងឺឲ្យមានប្រសិទ្ធភាព។ និយាមនៃការថែទាំនេះត្រូវបានដាក់ឲ្យប្រើប្រាស់នៅទូទាំងប្រព័ន្ធសុខាភិបាលសាធាណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទាំងក្នុងក្របខ័ណ្ឌក្រសួងសុខាភិបាល និង ក្រសួងស្ថាប័នរដ្ឋដទៃទៀតព្រមទាំងអង្គការសមាគម និង ដៃគូអភិវឌ្ឍរួមទាំង វិស័យឯកជននានាដោយផ្តោតលើ ការអនុវត្តន៍និងការបែងចែកតួនាទី គិលានុបដ្ឋាកបឋម បរិញ្ញាបត្ររងគិលានុបដ្ឋាក និង បរិញ្ញាបត្រគិលានុបដ្ឋាកក្នុងវិជ្ជាជីវៈនៃការងារថែទាំអ្នកជំងឺ ។

ក្រសួងសុខាភិបាលសូមណែនាំគិលានុបដ្ឋាក-យិកាគ្រប់កម្រិតជំនាញបច្ចេកទេសទាំងអស់ត្រូវប្រតិបត្តិ **និយាមនៃការថែទាំអ្នកជំងឺ**នេះឲ្យបានទូលំទូលាយនិងហ្មត់ចត់ក្នុងការថែទាំជំងឺគ្រប់ប្រភេទនិងគ្រប់ស្ថានភាពជូនប្រជាពលរដ្ឋប្រកបដោយគុណភាពខ្ពស់៕

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៥

**អគ្គនាយកបច្ចេកទេសសុខាភិបាល**

# សេចក្តីថ្លែងអំណរគុណ

និយាមនៃការថែទាំអ្នកជំងឺនេះត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាល និងមានការជួយគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីអង្គការ WHO AHC Pittsburgh University, American Nurses Association. ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកស្រីសាស្ត្រាចារ្យ លោក លោកស្រី និងអ្នកនាងកញ្ញាដែលមានរាយនាមខាងក្រោម៖

**ក្រុមប្រឹក្សាបច្ចេកទេសនៃក្រសួងសុខាភិបាល៖**

១.ឯកឧត្តមសាស្ត្រាចារ្យ **ឆា ក្រួយ** រដ្ឋលេខាធិការក្រសួងសុខាភិបាល

២.លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យ

៣.លោកស្រីសាស្ត្រាចារ្យ **គាត ត្អួច** ប្រធាននាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស

៤.Mr. Richard Henker PhD, RN, CRNA, FAAN, Professor, Department of Nurse Anesthesia School of Nursing, University of Pittsburgh.

៥.Ms. Carol J. Bickford, PhD, RN-BC, CPHIMS, FAAN, Senior Policy Fellow, Department of Nursing Practice & Work Environment, American Nurses Association.

**ក្រុមការងារបច្ចេកទេសអភិវឌ្ឍដែនកំណត់និងនិយាមនៃការថែទាំអ្នកជំងឺ៖**

១. លោក **កុយ វីរីយ៉ា** ប្រធានការិយាល័យគិលានុបដ្ឋាកនិងឆ្មប និងជាប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ

២. លោកស្រី **ប្រាក់ ម៉ានីឡា** ប្រធានក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកុមារអង្គរ

៣. លោក **អ៊ុន សាន** អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ

៤. លោកវេជ្ជ **មុយ ស៊ាងហ៊ន់** អនុប្រធានការិយាល័យគិលានុបដ្ឋាកនិងឆ្មប

៥. លោកស្រី **ហែម ណារី** អនុប្រធានការិយាល័យគិលានុបដ្ឋាកនិងឆ្មប

៦. លោក **លឹម ឧុត្តី** ប្រធានការិយាល័យបច្ចេកទេសសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

៧. លោកស្រី **ម៉ៅ ម៉ាលីវណ្ណា** មន្ទីរពេទ្យកាល់ម៉ែត

៨. លោកស្រី **ម៉ៅ តាន់ណារី** ប្រធានគិលានុបដ្ឋាកមន្ទីរពេទ្យបង្អែកក្រុងភ្នំពេញ

៩. លោក **យក់ សុត្ថា** ប្រធានគិលានុបដ្ឋាកមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង

១០. លោក **ជា ម៉ុឡូ** សាលាមធ្យមសិក្សាភូមិភាគបាត់ដំបង

១១. លោក **ឃុន កុម៉ា** សាលាមធ្យមសិក្សាភូមិភាគកំពង់ចាម

១២. លោកស្រី **លឹម ថាវរ៉ា** ប្រធានគិលានុបដ្ឋាកមន្ទីរពេទ្យកុមារជាតិ

១៣. លោក **ទេស កេត្យា** សាលាមធ្យមសិក្សាភូមិភាគកំពត

១៤. លោក **យ៉ង់ ណារ៉េម** សាលាមធ្យមសិក្សាភូមិភាគស្ទឹងត្រែង

១៥. លោកស្រី **កង ឡុងធវីវណ្ណា** មន្ទីរពេទ្យព្រះកុសុមៈ

១៦. លោក **ប៉ាក់ សុភាគ** មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត។

# បញ្ជីមាតិកា

**អារម្ភកថា** .....ii

**សេចក្តីថ្លែងអំណរគុណ** .....iii

**និយាមនៃការថែទាំ និងសមត្ថកិច្ច**.....1

**១.និយាមនៃការអនុវត្ត** .....1

*និយាមទី១: ការប៉ាន់ប្រមាណ*.....1

*និយាមទី២: រោគវិនិច្ឆ័យ*.....2

*និយាមទី៣: ផែនការ* .....3

*និយាមទី៤: ការធ្វើអន្តរាគមន៍* .....5

*និយាមទី៥: ការវាយតម្លៃ*.....7

**២. និយាមនៃប្រសិទ្ធភាពការងារវិជ្ជាជីវៈ** .....8

*និយាមទី៦: សីលធម៌គិលានុបដ្ឋាកអនុវត្តប្រកបដោយសីលធម៌*.....6

*និយាមទី៧: ការបណ្តុះបណ្តាលបន្ត*.....8

*និយាមទី៨: ការអនុវត្តដោយផ្អែកលើភស្តុតាងនិងការស្រាវជ្រាវ*.....10

*និយាមទី៩: គុណភាពនៃការអនុវត្តន៍*.....9

*និយាមទី១0: ការទំនាក់ទំនង*.....10

*និយាមទី១១: ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង*.....12

*និយាមទី១២: ការប្រើប្រាស់ធនធាន* .....13

*និយាមទី១៣: ការសម្របសម្រួលក្នុងការថែទាំ* .....14

*និយាមទី១៤: ការអប់រំនិងលើកកម្ពស់សុខភាព*.....18

# និយាមនៃការថែទាំនិងសមត្ថកិច្ច

## ១-និយាមនៃការអនុវត្ត:

*<u>និយាមទី១: ការប៉ាន់ប្រមាណ</u>*

គិលានុបដ្ឋាកត្រូវធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឲ្យបានច្បាស់លាស់ស៊ីជម្រៅសមស្រប ទៅនឹងសុខភាពអ្នកជំងឺ ឬស្ថានភាពរបស់អ្នកជំងឺ។

*ក. <u>គិលានុបដ្ឋាកបឋម</u>៖*

គិលានុបដ្ឋាកបឋមត្រូវ៖

- ប្រមូលទិន្នន័យមានលក្ខណៈជាប្រព័ន្ធដោយធ្វើការប៉ាន់ប្រមាណដំណើរការនៃ មុខងារសុខភាពផ្លូវកាយ និង ផ្លូវចិត្តដោយគិតចាប់ពីពេលទទួលអ្នកជំងឺឲ្យសម្រាកពេទ្យ និង ពេលចាប់ផ្ដើមការព្យាបាល។

*ខ.<u>បរិញ្ញាបត្ររងគិលានុបដ្ឋាក</u>*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម<u>**បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ**</u>៖

- ប្រមូលទិន្នន័យបន្ថែមទៀតដោយធ្វើការប៉ានប្រមាណពី ផ្លូវអារម្មណ៍ ការយល់ដឹង អាយុ ប្រពៃណីបរិស្ថានភេទជំនឿសាសនាទំនាក់ទំនងបុគ្គល និងសេដ្ឋកិច្ចសង្គម។
- ពិនិត្យរកគុណតម្លៃ របស់អ្នកជំងឺ ចំណង់ចំណូលចិត្ត តម្រូវការ និង ចំណេះដឹងនៃស្ថានភាពថែទាំសុខភាពរួមទាំងតម្រូវការផ្នែករូបវន្តដូចជាអាហាររូបត្ថម្ភអនាម័យ។ល។ ដោយមានការចូលរួមពីអ្នកជំងឺក្រុមគ្រួសារនិងអ្នកផ្ដល់សេវាថែទាំផ្សេងទៀតឲ្យបានសមរម្យ។
- ធ្វើការប៉ាន់ប្រមាណក្រុមគ្រួសារនិងផលប៉ះពាល់ដល់អ្នកជំងឺ។

*គ.<u>បរិញ្ញាបត្រគិលានុបដ្ឋាក</u>*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក<u>**បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ**</u>៖

- ប្រើប្រាស់ភស្តុតាងបច្ចេកទេសនៃការប៉ាន់ប្រមាណសម្ភារៈ និងឧបករណ៍ផ្សេងៗទៀតឲ្យបានសមស្រប។
- បកស្រាយរោគវិនិច្ឆ័យនិងទម្រង់ការដែលទាក់ទងទៅនឹងស្ថានភាពរបស់អ្នកជំងឺ។

*និយាមទី២: ការធ្វើរោគវិនិច្ឆ័យ*

គិលានុបដ្ឋាកធ្វើការវិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យឬបញ្ហារបស់អ្នកជំងឺ។

*ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- កំណត់រកនិងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ និងធ្វើរបាយការណ៍ឲ្យបានសមស្របជូនទៅអ្នកថែទាំសុខភាពឯទៀត។

*ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋមបរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ៖

- ទាញយករោគវិនិច្ឆ័យ ឬបញ្ហាពីទិន្នន័យនៃការប៉ាន់ប្រមាណ។
- ធ្វើឲ្យមានសុពលភាពរោគវិនិច្ឆ័យ ឬបញ្ហាជាមួយអ្នកប្រើប្រាស់សេវាថែទាំសុខភាព ក្រុមគ្រួសារ និង អ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀត ទៅតាម កាលៈទេសៈ ឲ្យបានសមរម្យ។
- កត់ត្រារោគវិនិច្ឆ័យដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការ និងកំណត់លទ្ធផលរំពឹងទុកព្រមទាំងធ្វើផែនការថែទាំអ្នកជំងឺ។

*គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក**បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖**

- ប្រើប្រាស់ទិន្នន័យដែលស្មុគ្រស្មាញនិងព័ត៌មានដែលបានមកពីការសម្ភាសន៍ ការពិនិត្យ និងដំណើរការធ្វើរោគវិនិច្ឆ័យដើម្បីកំណត់រោគវិនិច្ឆ័យ។
- ជួយបុគ្គលិកក្នុងការអភិវឌ្ឍ និងរក្សាសមត្ថភាពក្នុងដំណើរការធ្វើរោគវិនិច្ឆ័យ។

## *និយាមទី៣: ផែនការ*

គិលានុបដ្ឋាកបង្កើត ផែនការដោយកំណត់ យុទ្ធសាស្ត្រ និង ដាក់ជម្រើសថែទាំផ្សេងៗដើម្បីឈានទៅសម្រេចលទ្ធផលរំពឹងទុក។

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- ផ្តល់ការគាំទ្រសម្រាប់ការកំណត់អំពីការធ្វើផែនការនៃការថែទាំអ្នកជំងឺ។
- កត់ត្រាផែនការដោយប្រើ ភាសាស្តង់ដា ឬ ដោយប្រើពាក្យបច្ចេកទេស។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម**បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ**៖

- បង្កើតផែនការថែទាំសម្រាប់អ្នកជំងឺម្នាក់ៗ ជាលក្ខណៈបុគ្គល ក្រុមគ្រួសារ និងលក្ខណៈស្ថានភាពរបស់អ្នកជំងឺព្រមទាំងគុណតម្លៃជំនឿសាសនា និង ការគោរពការថែទាំសុខភាព ចំណង់ចំណូលចិត្ត ការជ្រើសរើសកម្រិតនៃការលូតលាស់ របៀបនៃការដោះស្រាយបញ្ហាវប្បធម៌ បរិស្ថានរបស់អ្នកជំងឺ និងបច្ចេកវិជ្ជាដែលមានស្រាប់។
- បង្កើតផែនការដែលជាអាទិភាពសម្រាប់អ្នកជំងឺ ក្រុមគ្រួសារ និងសម្រាប់អ្នកផ្សេងទៀតឲ្យបានសមស្រប។
- ដាក់បញ្ចូលយុទ្ធសាស្ត្រក្នុងផែនការដោយបញ្ជាក់អំពីរោគវិនិច្ឆ័យ ឬបញ្ហានីមួយៗ។ យុទ្ធសាស្ត្រនេះសម្រាប់៖

    ១-លើកកម្ពស់ និងធ្វើឲ្យប្រសើរសុខភាព

    ២-បង្ការជំងឺគ្រោះថ្នាក់ និងជំងឺឆ្លងផ្សេងៗ

    ៣-សម្រាលការឈឺចាប់

    ៤-គាំទ្រការថែទាំចំពោះអ្នកជំងឺស្លាប់។

- ដាក់បញ្ចូលយុទ្ធសាស្ត្រសម្រាប់ថែទាំសុខភាព ឬរយៈពេលអាយុ (ចាប់ពីពេលកើតដល់ពេលស្លាប់)។
- ផ្តល់ការថែទាំបន្តនៅក្នុងផែនការ។
- ដាក់បញ្ចូលភាពទាន់ពេលនៃការធ្វើអន្តរាគមន៍នៅក្នុងផែនការ។
- ធ្វើការពិចារណាអំពីផលប៉ះពាល់ថវិកានៃផែនការថែទាំចំពោះអ្នកជំងឺ ក្រុមគ្រួសារអ្នកថែទាំ ឬអ្នកដែលទទួលរងការប៉ះពាល់ដទៃទៀត។

- ប្រើប្រាស់ផែនការដើម្បី ផ្តល់ការណែនាំដល់ សមាជិក នៃ ក្រុមថែទាំសុខភាពដទៃទៀត។
- កែសម្រួលផែនការទៅតាមការប៉ាន់ប្រមាណអ្នកជំងឺដើម្បីឲ្យឆ្លើយតបទៅនឹងរង្វាស់លទ្ធផលនៃការថែទាំ។

*គ.<u>បរិញ្ញាបត្រគិលានុបដ្ឋាក</u>*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*<u>បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖</u>*

- ធ្វើបច្ចុប្បន្នភាពភស្តុតាងនិន្នាការ និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។
- កំណត់យុទ្ធសាស្ត្រនៃការប៉ាន់ប្រមាណរោគវិនិច្ឆ័យ និងការធ្វើអន្តរាគមន៍នៃការព្យាបាលដោយផ្អែកលើភស្តុតាងថ្មីៗរួមមានទិន្នន័យការស្រាវជ្រាវឯកសារយោង និងចំណេះដឹងផ្នែកគ្លីនិករបស់អ្នកជំនាញ។
- ជ្រើសរើស ឬរៀបចំយុទ្ធសាស្ត្រដើម្បីបំពេញតម្រូវការជាច្រើននៃភាពស្មុគ្រស្មាញរបស់អ្នកជំងឺ។

## *និយាមទី៤: ការធ្វើអន្តរាគមន៍*

គិលានុបដ្ឋាកត្រូវធ្វើអន្តរាគមន៍ដើម្បីថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់។

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- ផ្តល់ការគាំទ្រក្នុងការអនុវត្តន៍ផែនការថែទាំអ្នកជំងឺដែលបានកំណត់។

### *ខ.បរិញ្ញាបត្រវ៉េគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្រវ៉េគិលានុបដ្ឋាកត្រូវ៖*

- សន្មត់ពីការទទួលខុសត្រូវដើម្បីសុវត្ថិភាពនិងប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍តាមផែនការ។
- សហការជាមួយបុគ្គលក្រុមគ្រួសារអ្នកដែលមានដៃគូ និងអ្នកថែរក្សាដទៃទៀតឲ្យបានសមរម្យ ដើម្បីឲ្យការធ្វើអន្តរាគមន៍មានសុវត្ថិភាពជាក់លាក់និងទាន់ពេលវេលា។
- បង្ហាញអំពីអាកប្បកិរិយាថែរក្សាចំពោះអ្នកជំងឺអ្នកដែលមានដៃគូ និងក្រុមមនុស្សដែលទទួលបានការថែទាំ។
- ប្រើប្រាស់បច្ចេកវិទ្យាដើម្បីវាស់វែងកត់ត្រាការទាញយកទិន្នន័យការអនុវត្តន៍ដំណើរការថែទាំ និងធ្វើឲ្យប្រសើរឡើងនូវការអនុវត្តន៍ការងារថែទាំអ្នកជំងឺ។
- ផ្តល់ការថែទាំទាំងស្រុងដែលឆ្លើយតបទៅនឹង តម្រូវការនៃ ប្រជាជននានាគ្រប់កម្រិតអាយុ។
- និយាយគាំទ្រសម្រាប់ថែទាំសុខភាពដែលជាចំណុចចាំបាច់ដើម្បី បំពេញតម្រូវការរបស់អ្នកជំងឺ ដោយសង្កត់ធ្ងន់ទៅលើតម្រូវការប្រជាជននានា។
- ប្រើប្រាស់ចំណេះដឹងឲ្យបានសមរម្យអំពីបញ្ហាសុខភាពសំខាន់ៗ និង ភាពផ្សេងគ្នានៃវប្បធម៌ក្នុងការធ្វើអន្តរាគមន៍តាមផែនការនៃការថែទាំ។
- ប្រើប្រាស់បច្ចេកវិទ្យាការថែទាំសុខភាពដែលមានស្រាប់ដើម្បីឲ្យអ្នកជំងឺទទួលសេវា និង ធ្វើឲ្យលទ្ធផលរបស់អ្នកជំងឺកាន់តែប្រសើរឡើង។
- ប្រើប្រាស់ធនធាននិងប្រព័ន្ធផ្សេងៗនៅក្នុងគ្រឹះស្ថានថែទាំសុខភាព និង សហគមន៍ដើម្បីអនុវត្តផែនការបានសម្រេច។
- សហការជាមួយអ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀតពីមជ្ឈដ្ឋានផ្សេងៗដើម្បីធ្វើអន្តរាគមន៍ និងដាក់បញ្ចូលផែនការថែទាំ។

- សម្របសម្រួលតាមរបៀបផ្សេងគ្នានៃការទំនាក់ទំនងដែលប្រើដោយអ្នកជំងឺក្រុមគ្រួសារ និង អ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀត។
- ដាក់បញ្ចូលការប្រតិបត្តិថែទាំសុខភាពតាមបែបប្រពៃណីសាសនា និង តាមបែបបទ្នាប់បន្សំ ផ្សេងទៀតដែលសមស្រប។
- អនុវត្តផែនការថែទាំតាម កាលវេលា ដោយផ្អែកលើ គោលដៅ សុវត្ថិភាពសម្រាប់ អ្នកជំងឺ។
- លើកកម្ពស់សមត្ថភាពរបស់អ្នកជំងឺ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ការចូលរួមនិងដោះស្រាយ បញ្ហា។
- កត់ត្រារាល់ការធ្វើអន្តរាគមន៍ និងការកែលម្អព្រមទាំងការផ្លាស់ប្តូរឬលុបចោលផែនការថែទាំ ដែលបានកំណត់។

*គ.<u>បរិញ្ញាបត្រគិលានុបដ្ឋាក</u>*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*<u>បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ</u>*៖

- ប្រើប្រាស់អន្តរាគមន៍ដោយផ្អែកលើភស្តុតាង និងព្យាបាលរោគវិនិច្ឆ័យ ឬបញ្ហាជាក់លាក់ របស់អ្នកជំងឺ។
- សម្របសម្រួលការប្រើប្រាស់ប្រព័ន្ធក្នុងអង្គភាព និងធនធានសហគមន៍ដើម្បីអនុវត្តផែនការ ថែទាំអ្នកជំងឺ។
- គាំទ្រការ សហការ ជាមួយ សហសេវិកដទៃទៀត ដើម្បី អនុវត្តផែនការនៃ ការថែទាំឲ្យបាន សម្រេច។
- ដាក់បញ្ចូលចំណេះដឹង និងយុទ្ធសាស្ត្រថ្មីៗដើម្បីផ្តួចផ្តើមធ្វើការផ្លាស់ប្តូរការអនុវត្តន៍ការ ថែទាំក្នុងករណីលទ្ធផលដែលរំពឹងទុកមិនទទួលបានជោគជ័យ។
- ប្រើប្រាស់ជំនាញនៃការប្រាស្រ័យទាក់ទងជឿនលឿនដើម្បី លើកកម្ពស់ការទំនាក់ទំនងរវាង គិលានុបដ្ឋាកនិងអ្នកជំងឺក្នុងគោលបំណងផ្តល់បរិបទសម្រាប់ការពិភាក្សាអំពី បទពិសោធន៍ នៃអ្នកប្រើប្រាស់សេវាថែទាំសុខភាពនិងលើកកម្ពស់លទ្ធផលរបស់អ្នកទទួលសេវាសុខាភិបាល។
- ចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងបន្តការលើកកម្ពស់ប្រព័ន្ធដែលគាំទ្រនៃការអនុវត្តន៍ ផែនការ។

## *និយាមទី៥: ការវាយតម្លៃ*

គិលានុបដ្ឋាកធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបាន។

### *ក.គិលានុបដ្ឋាកបឋម*

- ផ្តល់ការគាំទ្រក្នុងការអនុវត្តន៍ផែនការថែទាំដែលបានកំណត់។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវៈ*

- បន្តធ្វើការវាយតម្លៃលក្ខណៈជាប្រព័ន្ធ និង ជាលក្ខណៈបែបលក្ខខណ្ឌអំពីលទ្ធផលទាក់ទងទៅនឹងរចនាសម្ព័ន្ធនិងដំណើរការដែលកំណត់ដោយផែនការថែទាំ និងតាមពេលវេលាដែលបានគ្រោងទុក។
- សហការជាមួយអ្នកជំងឺនិងអ្នកផ្សេងទៀតដែលជាប់ទាក់ទងទៅនឹងការថែទាំ ឬទៅនឹងស្ថានភាពនៃដំណើរការវាយតម្លៃ។
- ប្រើប្រាស់ទិន្នន័យដែលបានពីការប៉ាន់ប្រមាណបន្តដើម្បី ពិនិត្យឡើងវិញ រោគវិនិច្ឆ័យលទ្ធផល ផែនការនិងអន្តរាគមន៍តាមការចាំបាច់។
- ចូលរួមក្នុងការប៉ាន់ប្រមាណនិងធានាថា ការទទួលខុសត្រូវសមរម្យក្នុងការប្រើអន្តរាគមន៍ដើម្បីកាត់បន្ថយការព្យាបាលណាដែលមិនចាំបាច់ និងកាត់បន្ថយការឈឺចាប់។
- កត់ត្រាលទ្ធផលនៃការវាយតម្លៃនៅក្នុងឯកសារអ្នកជំងឺ។

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវៈ*

- ធ្វើការវាយតម្លៃ អ្នកជំងឺប្រសិទ្ធភាពនៃយុទ្ធសាស្ត្រដែលបានកំណត់ទាក់ទងទៅនឹងការឆ្លើយតបរបស់អ្នកជំងឺនិងលទ្ធផលរំពឹងទុកដែលសម្រេចបាន។
- បង្ហាញលទ្ធផលដល់អ្នកទទួលសេវាក្រុមគ្រួសារ និងអ្នកពាក់ព័ន្ធដទៃទៀតដោយផ្អែកតាមបញ្ញត្តិផ្សេងៗ។
- វាយតម្លៃភាពត្រឹមត្រូវនៃរោគវិនិច្ឆ័យនិងប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍ និងភាពប្រែប្រួលទាក់ទងទៅនឹងលទ្ធផលរំពឹងទុករបស់អ្នកជំងឺដែលទទួលបាន។
- ធ្វើការសំយោគលទ្ធផលនៃការវាយតម្លៃដើម្បី កំណត់ប្រសិទ្ធភាពនៃផែនការសម្រាប់អ្នកជំងឺ ក្រុមគ្រួសារ ក្រុមសហគមន៍ និង ស្ថាប័នផ្សេងៗ។
- កែសម្រួលផែនការទៅតាមប្រសិទ្ធភាពនៃការព្យាបាល។
- ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដើម្បីធ្វើការផ្លាស់ប្តូរដំណើរការ ឬ រចនាសម្ព័ន្ធព្រមទាំងគោលនយោបាយ ទម្រង់ការឬពិធីសារឲ្យបានសមរម្យ។

## ២. និយាមនៃប្រសិទ្ធភាពការងារវិជ្ជាជីវៈ

*<u>និយាមទី៦: សីលធម៌គិលានុបដ្ឋាកអនុវត្តប្រកបដោយសីលធម៌</u>*

*ក.<u>គិលានុបដ្ឋាកបឋម</u>*

គិលានុបដ្ឋាកបឋមត្រូវះ

- ផ្តល់ការថែទាំប្រាកដប្រជាដោយរក្សា បង្ការគោរពនិងការពារឯករាជ្យភាព សេចក្តីថ្លៃថ្នូរសិទ្ធិ តម្លៃជំនឿប្រពៃណីវប្បធម៌ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ។

*ខ.<u>បរិញ្ញាបត្ររងគិលានុបដ្ឋាក</u>*

បន្ថែមលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*<u>បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវះ</u>*

- ប្រើប្រាស់ក្រមសីលធម៌ដើម្បីជាគោលការណ៍ណែនាំសម្រាប់ការអនុវត្ត។
- ទទួលស្គាល់ភាពសំខាន់របស់អ្នកជំងឺនិង ក្រុមគ្រួសារដែលជាចំណុចស្នូលនៃសមាជិកក្រុមបុគ្គលិកសុខាភិបាលនីមួយៗ។
- ជួយអ្នកជំងឺឲ្យធ្វើការសម្រេចចិត្តដោយខ្លួនឯង។
- រក្សាការព្យាបាល និង ទំនាក់ទំនងរវាង អ្នកជំងឺ និង គិលានុបដ្ឋាកឲ្យបានសមរម្យក្នុង កម្រិតតួនាទីវិជ្ជាជីវៈ។
- ប្រកាន់ខ្ជាប់អាកប្បកិរិយា មិនវិនិច្ឆ័យ ដោយ មិនធ្វើការស្តីបន្ទោស មិនបំភ័យឬ មិនប្រកែកជាមួយអ្នកជំងឺ។
- ចូលរួមដោះស្រាយបញ្ហាសីលធម៌ដែលទាក់ទងនឹង អ្នកជំងឺ សហសេវិក ក្រុមក្នុងប្រព័ន្ធសហគមន៍ និង អ្នកគ្រប់គ្រង។
- ចាត់វិធានការសមស្រប ក្នុងពេលមានការកើតឡើងនូវ ភាពមិនស្របច្បាប់ អសីលធម៌ ឬ អាកប្បកិរិយា មិនសមរម្យដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ផលប្រយោជន៍ឬស្ថានភាពរបស់អ្នកជំងឺ។
- និយាយឲ្យបានច្បាស់ និង នៅពេលណាដែលសមរម្យដើម្បីសាកសួរអំពីការប្រតិបត្តិថែទាំសុខភាពក្នុងពេលចាំបាច់ដើម្បី សុវត្ថិភាព និង ការលើកកម្ពស់ គុណភាព ការថែទាំអ្នកជំងឺ។
- និយាយជំនួសអ្នកជំងឺដើម្បីសមធម៌នៃការថែទាំអ្នកជំងឺ។

*គ.<u>បរិញ្ញាបត្រគិលានុបដ្ឋាក</u>*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*<u>បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវះ</u>*

- ចូលរួមក្នុងក្រុមអន្តរវិជ្ជាជីវៈដើម្បី ដោះស្រាយការប្រឈមផ្នែកសីលធម៌ ផលប្រយោជន៍ និងលទ្ធផល។
- ផ្តល់ព័ត៌មានអំពីការប្រឈមផលប្រយោជន៍ និងលទ្ធផលនៃការថែទាំព្យាបាលដល់អ្នកជំងឺដើម្បីអនុញ្ញាតឲ្យអ្នកជំងឺធ្វើការសម្រេចចិត្តធ្វើកិច្ចសន្យា ឬបដិសេធការព្យាបាល។

## *និយាមទី៧: ការបណ្តុះបណ្តាលបន្ត*

គិលានុបដ្ឋាកត្រូវបន្តការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឲ្យបានជាប្រចាំ

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវៈ

- ធានាលើការទទួលខុសត្រូវក្នុងការ បន្តការសិក្សាវិជ្ជាជីវៈរបស់ខ្លួនដើម្បី អភិវឌ្ឍ និង រក្សាសមត្ថភាពរបស់ខ្លួនជានិច្ច។
- ឆ្លៀតឱកាសសិក្សាជាមួយសហសេវិកដើម្បីចូលរួមធ្វើការថែទាំសុខភាព។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវៈ*

- ធានាលើការទទួលខុសត្រូវក្នុងបន្តការសិក្សាវិជ្ជាជីវៈរបស់ខ្លួនដើម្បីអភិវឌ្ឍនិងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច។
- ឆ្លៀតឱកាសសិក្សាជាមួយសហសេវិកដើម្បីចូលរួមធ្វើការថែទាំសុខភាព។

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវៈ*

- ធ្វើការសិក្សាឡើងវិញជាទៀងទាត់ចំពោះការអនុវត្តរបស់ខ្លួនដោយភ្ជាប់ទៅនឹងការឆ្លុះបញ្ចាំងការពិនិត្យផ្នែក គ្លីនិក ការវាយតម្លៃ និង ស្វែងរកជំនួយនៃ ការពិនិត្យឡើងវិញពីសហសេវិក។

## *និយាមទី៨: ការអនុវត្តដោយប្រើប្រាស់ភស្តុតាងនិងការស្រាវជ្រាវ*

គិលានុបដ្ឋាកធ្វើ ការស្រាវជ្រាវ និង យកលទ្ធលនៃ ការស្រាវជ្រាវដើម្បី ធ្វើការផ្លាស់ប្តូរការអនុវត្តឲ្យបានសមស្រប។

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- ជួយ និងចូលរួមរាល់សកម្មភាពនៃការសិក្សាស្រាវជ្រាវ។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ៖*

- គាំទ្រការប្រើប្រាស់ភស្តុតាងឬលទ្ធផលក្នុងពេលអនុវត្តការថែទាំអ្នកជំងឺ

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖*

- ប្រើប្រាស់ចំណេះដឹងថ្មីៗដែលផ្អែកលើ ភស្តុតាងដោយយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើជាគោលការណ៍ណែនាំសម្រាប់អនុវត្ត។
- បង្ហាញភស្តុតាងនៅពេលធ្វើការផ្លាស់ប្តូរការថែទាំអ្នកជំងឺ។
- ចូលរួមក្នុងការ បណ្តុះបណ្តាល និង បំពេញតួនាទីឲ្យបានសមរម្យក្នុងការ បង្កើតការថែទាំអ្នកជំងឺដោយផ្អែកលើភស្តុតាងតាមរយៈការសិក្សាស្រាវជ្រាវ។
- ចែករំលែកចំណេះដឹងបទពិសោធន៍ និង លទ្ធផលនៃការសិក្សាស្រាវជ្រាវជាលក្ខណៈផ្ទាល់ខ្លួន ឬជាក្រុមជាមួយសហសេវិកនិងអ្នករួមការងារដទៃទៀត។

## *និយាមទី៩: គុណភាពនៃការអនុវត្ត*

គិលានុបដ្ឋាកចូលរួម លើកកម្ពស់គុណភាព នៃ ការអនុវត្ត ការងារថែទាំអ្នកជំងឺ ជាប្រចាំ។

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវៈ

- ប្រើប្រាស់ការច្នៃប្រឌិត និង បង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវៈ*

- បង្ហាញគុណភាពនៃ ការថែទាំ តាមរយៈការប្រើប្រាស់ឯកសារដែលបានអនុវត្តដំណើរការថែទាំក្នុងរូបភាពប្រកបដោយការទទួលខុសត្រូវ មានគណនេយ្យភាព និងសីលធម៌។
- ចូលរួមក្នុងការលើកកម្ពស់គុណភាពនៃការថែទាំដែលមានសកម្មភាពដូចតទៅៈ
  - ១-កំណត់អំពីទិដ្ឋភាពសំខាន់ៗដើម្បីត្រួតពិនិត្យគុណភាពថែទាំអ្នកជំងឺ
  - ២-ប្រើប្រាស់ខ្នាតរង្វាស់ដើម្បីត្រួតពិនិត្យ គុណភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃការថែទាំ
  - ៣-ប្រមូលទិន្នន័យដើម្បីត្រួតពិនិត្យគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារថែទាំ
- ចូលរួមឬដឹកនាំក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយតម្លៃ និងការត្រួតពិនិត្យកិច្ចការមិនចាំបាច់
- កំណត់បញ្ហាដែលបានកើតឡើងក្នុងការងារប្រចាំថ្ងៃដើម្បីកែលម្អដំណើរការដែលគ្មានប្រសិទ្ធភាព។

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវៈ*

- វិភាគគុណភាពទិន្នន័យដើម្បីកំណត់ឱកាសក្នុងការលើកកម្ពស់ការអនុវត្តន៍ការងារថែទាំអ្នកជំងឺ
- បង្កើតសេចក្តីណែនាំផ្សេងៗដើម្បី លើកកម្ពស់ ការអនុវត្តន៍ ឬ លទ្ធផលការងារថែទាំ។
- ប្រតិបត្តិសកម្មភាពផ្សេងៗដើម្បីជំរុញការលើកម្ពស់ គុណភាពនៃ ការអនុវត្តន៍ការងារថែទាំ។
- បង្កើតក្រុមប្រតិបត្តិនិងវាយតម្លៃគោលនយោបាយពិធីសារ និងគោលការណ៍ណែនាំដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ។
- ចូលរួមឬដឹកនាំក្រុមអន្តរវិជ្ជាជីវៈដើម្បីវាយតម្លៃការថែទាំគ្លីនិក ឬសេវាថែទាំសុខភាព។
- វិភាគកត្តាដែលពាក់ព័ន្ធនឹងគុណភាពសុវត្ថិភាព និង ប្រសិទ្ធភាពនៃការថែទាំអ្នកជំងឺ។

- វិភាគប្រព័ន្ធគ្រប់គ្រងរបស់មន្ទីរពេទ្យដែលអាចជាឧបសគ្គ និង រំខានដល់លទ្ធផលគុណភាពរបស់អ្នកជំងឺ។
- ប្រតិបត្តិដំណើរការដើម្បីបំបាត់ឬកាត់បន្ថយឧបសគ្គនៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់មន្ទីរពេទ្យ។
- ផ្តល់ភាពជាអ្នកដឹកនាំក្នុង ការបង្កើត និង ប្រតិបត្តិនៃការ លើកកម្ពស់ គុណភាពការថែទាំ។
- បង្កើតវិធីសាស្រ្តថ្មីៗដែលជាកិច្ចខិតខំប្រឹងប្រែងផ្លាស់ប្តូរការអនុវត្ត និងការលើកកម្ពស់លទ្ធផលថែទាំសុខភាព។
- ប្រើប្រាស់លទ្ធផលនៃការលើកកម្ពស់គុណភាពក្នុងការផ្តួចផ្តើមការផ្លាស់ប្តូរការអនុវត្តន៍ និងធ្វើការកែសម្រួលប្រព័ន្ធផ្តល់សេវាថែទាំអ្នកជំងឺក្នុងករណីចាំបាច់។
- ជួយពិនិត្យឡើងវិញ និងកែលម្អពិធីសារនិងគោលនយោបាយរបស់មន្ទីរពេទ្យ។
- ជួយធ្វើការបណ្តុះបណ្តាល និងធ្វើការអភិវឌ្ឍវិជ្ជាជីវៈដល់និស្សិតនិងសហសេវិកនៅនឹកន្លែងធ្វើការ
- ផ្តល់ពត៌មានត្រឡប់ផ្តល់ការណែនាំដើម្បីធ្វើការផ្លាស់ប្តូរ និងដោះស្រាយឲ្យមានប្រសិទ្ធភាពរាល់ផលប៉ះពាល់ដល់ ការផ្លាស់ប្តូរចំពោះ ការអនុវត្តន៍របស់ខ្លួន ឬ ចំពោះមន្ទីរពេទ្យ។

## *និយាមទី១0: ការទំនាក់ទំនង*

គិលានុបដ្ឋាកធ្វើទំនាក់ទំនងជាមួយ អ្នកជំងឺ ក្រុមគ្រួសារ និង មន្ត្រីសុខាភិបាលដទៃទៀត។

### *ក.គិលានុបដ្ឋាកបឋម:*

គិលានុបដ្ឋាកបឋមត្រូវះ

- ធ្វើការទំនាក់ទំនងជាមួយអ្នកជំងឺក្រុមគ្រួសារ និងបុគ្គលិកសុខាភិបាលដទៃទៀត។
- ប៉ាន់ប្រមាណពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសំភាសន៍អ្នកជំងឺ ក្រុមគ្រួសារ និង បុគ្គលិកសុខាភិបាលដ៏ទៃទៀត។

### *ខ.បរិញ្ញាបត្រវង៍គិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្រវង៍គិលានុបដ្ឋាកត្រូវះ*

- ធ្វើការប៉ាន់ប្រមាណពីទម្រង់នៃការទំនាក់ទំនងដែលចូលចិត្តរបស់អ្នកប្រើប្រាស់សេវាសុខាភិបាល ក្រុមគ្រួសារ និងសហាសេវិក។
- ប៉ាន់ប្រមាណជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលធ្វើការប្រាស្រ័យទាក់ទងជាមួយ អ្នកប្រើប្រាស់សេវាសុខាភិបាល ក្រុមគ្រួសារ និងសហាសេវិកដទៃទៀត។
- បន្តការស្វែងរក ការចូលរួមលើកកម្ពស់ ទំនាក់ទំនង និង ជំនាញដំណោះស្រាយជម្លោះ។
- ផ្តល់ព័ត៌មានជាក់លាក់ដល់អ្នកប្រើប្រាស់សេវាសុខាភិបាល ក្រុមគ្រួសារក្រុមអន្តរៈវិជ្ជាជីវៈ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីជួយបង្កើនភាពជឿជាក់លើសេវាសុខាភិបាល។
- សាកសួរអំពីហេតុផលគាំទ្រដំណើរការនៃការថែទាំ និងធ្វើការសម្រេចចិត្តនៅពេលដែលព័ត៌មានទាំងនោះមិនបានបង្ហាញដើម្បីជាប្រយោជន៍ដល់អ្នកជំងឺ។
- បង្ហាញអំពីការសង្កេត ឬការព្រួយបារម្ភដែលទាក់ទងការគ្រោះថ្នាក់ និងការភ័ន្តច្រឡំក្នុងការថែទាំ ឬបរិយាកាសនៃការអនុវត្តន៍ក្នុងកម្រិតសមរម្យ។
- រក្សាការទំនាក់ទំនងជាមួយ អ្នកផ្តល់សេវាដទៃទៀតដើម្បីកាត់បន្ថយការប្រឈមគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការបញ្ជូនការផ្លាស់ប្តូរក្នុងការផ្តល់ការថែទាំ។
- រួមចំណែកក្នុងទស្សនៈវិជ្ជាជីវៈរបស់ខ្លួនដោយធ្វើការ ពិភាក្សាជាមួយក្រុមវិជ្ជាជីវៈដទៃទៀត។

## *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក***បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖***

- ផ្តួចផ្តើមបង្កើត និងបញ្ឈប់ការទំនាក់ទំនងការព្យាបាលតាមរយៈការប្រើប្រាស់ទំនាក់ទំនងសមរម្យនិងអន្តរៈជំនាញទំនាក់ទំនងដើម្បី ថែរក្សាទំនាក់ទំនងដែលគោរពដល់ ដែនកំណត់រវាងអ្នកជំងឺនិងខ្លួនឯង។
- ស្តាប់អ្នកដទៃដោយប្រកាន់ ឥរិយាបថ មិនលំអៀងមិនវិនិច្ឆ័យគោរពទស្សនៈអ្នកដទៃ និងបង្កើនការសំដែងភាពខុសគ្នានៃគំនិត និងទស្សនៈផ្សេងៗ។
- ទំនាក់ទំនងច្បាស់លាស់មានភាពស៊ីសង្វាក់ និងភាពត្រឹមត្រូវនៃព័ត៌មានផ្ទាល់មាត់ ឬដោយការសរសេរបែបអេឡិចត្រូនិកដែលស្ថិតនៅក្នុងការទទួលខុសត្រូវក្នុងវិជ្ជាជីវៈ និង រក្សាការសម្ងាត់រាល់ការថែទាំនិងព្យាបាល។
- សហប្រតិបត្តិការក្នុងឥរិយាបថគោរពសមរម្យចំពោះ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនារបស់អតិថិជនក្រុមគ្រួសារនិងអ្នកដែលមានវប្បធម៌ខុសៗគ្នា។
- សម្របសម្រួល ក្នុងការប្រើប្រាស់ ទិន្នន័យ ឬ ផ្តល់ ទិន្នន័យសមរម្យដល់ បុគ្គលណាម្នាក់
- ទំនាក់ទំនងនិងចែករំលែកព័ត៌មានដែលពាក់ព័ន្ធរួមទាំងការពិនិត្យ អតិថិជន ក្រុមគ្រួសារនិងសមាជិកក្រុមសុខាភិបាលដែលពាក់ព័ន្ធនឹងការផ្តល់សេវា។

*និយាមទី១១: ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង*

គិលានុបដ្ឋាកប្រើប្រាស់ភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រងទៅ តាមស្ថានភាពឲ្យបានសមរម្យ។

*ក.គិលានុបដ្ឋាកបឋម:*

គិលានុបដ្ឋាកបឋមត្រូវៈ

- ចូលរួមជាមួយក្រុមការងារថែទាំសុខភាពដោយធ្វើការទំនាក់ទំនងជាមួយអ្នកដឹកនាំគ្រប់គ្រង និងចលនាឯកសារអ្នកជំងឺឲ្យបានត្រឹមត្រូវ។

*ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវៈ*

- លើកទឹកចិត្តអ្នកជំងឺក្រុមគ្រួសារនិងសហគមន៍ឲ្យចូលរួមក្នុងការព្យាបាល និងថែទាំអ្នកជំងឺ។
- ពិភាក្សាអំពីផលប្រយោជន៍សំខាន់ៗក្នុងស្ថានភាពសាមញ្ញៗ។
- ផ្តល់និងចូលរួមលើកកម្ពស់មន្ទីរពេទ្យ។
- ស្វែងរកការគាំទ្រនិងធ្វើសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធ។
- គ្រប់គ្រងអ្នកជំងឺចេញនិងចូល។
- គ្រប់គ្រងសម្ភារៈឱសថសម្រាប់ផ្តល់ឲ្យក្នុងការថែទាំ។
- គ្រប់គ្រងតារាងពេលវេលារបស់បុគ្គល។
- ជួយបង្កើតទស្សនៈវិស័យ គោលបំណង និង វត្ថុបំណងសម្រាប់ សកម្មភាពថែទាំអ្នកជំងឺ។

*គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវៈ*

- និយាយគាំទ្រ និង បំពេញមុខងារ ក្នុងដែនត្រួតពិនិត្យ ដើម្បីបង្កើត បរិស្ថានការងារវិជ្ជមាន
- យកលំនាំតាមស្ទីល ភាពជាអ្នកដឹកនាំ និង គម្រូផ្សេងៗទៅតាម ស្ថានភាពខុសៗគ្នា។
- ក្នុងពេលប្រឈមមុខនឹង ជម្លោះដោយមិនបានធ្វើការវិនិច្ឆ័យត្រូវប្រើប្រាស់ ប្រសិទ្ធភាពជំនាញទំនាក់ទំនង និងយន្តការដែលមានស្រាប់ដើម្បីសម្រេចបាននូវដំណោះស្រាយ។
- ចូលរួមជាមួយក្រុមដឹកនាំដោយជំរុញ គោលដៅដែលមានការលើកកម្ពស់ការគោរពនិងភាពជឿជាក់ក្នុងចំណោមក្រុមការងារ។
- សំដែងភាពជាអ្នកដឹកនាំក្នុងការចូលរួមនិងគាំទ្រដល់លទ្ធផលរំពឹងទុកដល់សមាជិកក្រុមដទៃទៀត
- កំណត់ចំណុចអាទិភាពករណីមានកិច្ចការច្រើន និងគ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធភាពខ្ពស់
- ធ្វើការសម្រេចចិត្តដើម្បីជាប្រយោជន៍សម្រាប់អ្នកជំងឺនិងមន្ទីរពេទ្យ។
- ដោះស្រាយបញ្ហាដែលកើតឡើងក្នុងការអនុវត្តដោយប្រើប្រាស់ទិន្នន័យថ្មីៗព័ត៌មានបានមកពីអ្នកជំងឺនិងសហសេវិក។

## *និយាមទី១២: ការប្រើប្រាស់ធនធាន*

គិលានុបដ្ឋាកប្រើប្រាស់ធនធានឲ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អ នៃ ការថែទាំអ្នកជំងឺ

### *ក.គិលានុបដ្ឋាកបឋម:*

គិលានុបដ្ឋាកបឋមត្រូវ៖

- ចូលរួមក្នុងការប្រើប្រាស់ធនធានឲ្យបានសមរម្យ។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ៖*

- ចូលរួមក្នុងការប្រើប្រាស់ធនធានឲ្យបានសមរម្យ

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖*

- ប៉ាន់ប្រមាណតម្រូវការនៃការថែទាំរបស់អ្នកទទួលសេវាជាលក្ខណៈបុគ្គល និងប៉ាន់ប្រមាណធនធានដែលមានស្រាប់ដើម្បីសម្រេចលទ្ធផលរំពឹងទុក។
- កំណត់អំពីតម្រូវការថែទាំរបស់អ្នកទទួលសេវាសក្តានុពលគ្រោះថ្នាក់ភាពស្មុគ្រស្មាញនៃកិច្ចការ និងលទ្ធផលនៃការរំពឹងទុកនៅពេលពិចារណាអំពីការប្រើប្រាស់ធនធាន។
- ផ្ទេរភារកិច្ចនៃការថែទាំអ្នកជំងឺទៅបុគ្គលិកថែទាំសុខភាពដទៃទៀតឲ្យបានសមរម្យស្របតាមច្បាប់ឬគោលនយោបាយ ឬគោលការណ៍ផ្សេងៗ។
- ធ្វើការកំណត់អំពីភស្តុតាងនៅពេលវាយតម្លៃធនធាន។
- និយាយគាំទ្រអំពីធនធានរួមទាំងបច្ចេកវិទ្យាដែលជំរុញការអនុវត្តន៍ការងារថែទាំអ្នកជំងឺ។
- កែលម្អការអនុវត្តន៍នៅពេល ចាំបាច់ដើម្បី លើកកម្ពស់កិច្ចសហការរវាងអ្នកទទួលសេវា អ្នកផ្តល់សេវា និងបច្ចេកវិទ្យា។
- ជួយអ្នកទទួលយកសេវានិងក្រុមគ្រួសារក្នុងការកំណត់និងធានាពីសេវាសមរម្យដើម្បីបញ្ជាក់អំពីតម្រូវការក្នុងការបន្តការថែទាំសុខភាព។
- ជួយអ្នកទទួលយកសេវានិងក្រុមគ្រួសារធ្វើការសម្រេចចិត្តអំពីកត្តាតម្លៃការប្រឈម និងផលប្រយោជន៍ពីការព្យាបាល និងការថែទាំអ្នកជំងឺ។

## *និយាមទី១៣: ការសម្របសម្រួលក្នុងការថែទាំ*

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- កត់ត្រាអំពីការសម្របសម្រួលនៃការថែទាំអ្នកជំងឺ។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ៖*

- រៀបចំសមាសភាគផែនការថែទាំអ្នកជំងឺ។
- គ្រប់គ្រងការថែទាំដើម្បីបង្កើនភាពម្ចាស់ការនិងគុណភាពជីវិតរបស់អ្នកជំងឺ។
- ជួយអ្នកទទួលសេវាសុខាភិបាលដើម្បីកំណត់អំពីលទ្ធភាពនៃជម្រើសក្នុងការថែទាំ។
- ទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារនិងបែបបទផ្សេងៗនៅពេលមានការផ្លាស់ប្តូរការថែទាំ
- និយាយជំនួសអ្នកជំងឺដោយរក្សាសេចក្តីថ្លៃថ្នូរ និង ការថែទាំប្រកបដោយមនុស្សធម៌ជាមួយក្រុមការងារអន្តរវិជ្ជាជីវៈ។

### *គ.បរិញ្ញាបត្រគិលានុបដ្ឋាក*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក*បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖*

- ប្រកាន់យកភាពជាអ្នកដឹកនាំក្នុងពេលសម្របសម្រួលអន្តរៈវិជ្ជាជីវៈសុខាភិបាល ដើម្បីផ្តល់សេវាថែទាំដល់អ្នកជំងឺ។
- ធ្វើសំយោគទិន្នន័យ និងព័ត៌មានដើម្បីបញ្ជាក់អំពីប្រព័ន្ធចាំបាច់និងវិធានការណ៍បន្តការគាំទ្រព្រមទាំងកែសម្រួលស្ថានភាពដែលនៅជុំវិញក្នុងករណីចាំបាច់។

## *និយាមទី១៨: ការអប់រំ និង ការលើកកម្ពស់សុខភាព*

គិលានុបដ្ឋាកបង្កើតផែនការស្តីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់យុទ្ធសាស្ត្រ ដើម្បីសម្រេចលទ្ធផលរំពឹងទុក។

### *ក.គិលានុបដ្ឋាកបឋម*

គិលានុបដ្ឋាកបឋមត្រូវ៖

- ផ្តល់ព័ត៌មាននិងអប់រំដល់អ្នកជំងឺអំពីការលើកកម្ពស់សុខភាព និងការបង្ការជំងឺ។

### *ខ.បរិញ្ញាបត្ររងគិលានុបដ្ឋាក*

បន្ថែមលើភារកិច្ចរបស់គិលានុបដ្ឋាកបឋម*បរិញ្ញាបត្ររងគិលានុបដ្ឋាកត្រូវ៖*

- ប្រើប្រាស់ព័ត៌មានបែបបច្ចេកវិទ្យាដើម្បីទំនាក់ទំនងអំពីការលើកកម្ពស់សុខភាព និងព័ត៌មានអំពីការបង្ការជំងឺចំពោះអ្នកជំងឺនៅគ្រប់ផ្នែក។
- ផ្តល់ព័ត៌មាននិងអប់រំអ្នកជំងឺអំពីផលប៉ះពាល់សុខភាពនិងផលរំខាននៃការព្យាបាល។
- ធ្វើការអប់រំសុខភាពដោយសង្កត់ទៅលើរបៀបនៃ ការរស់នៅប្រកបដោយផាសុខភាពដើម្បីកាត់បន្ថយអាកប្បកិរិយាប្រឈមមុខតម្រូវការសម្រាប់ការលូតលាស់សកម្មភាពរស់នៅប្រចាំថ្ងៃ និងការបង្ការខ្លួនឯងពីជំងឺផ្សេងៗ។
- ប្រើប្រាស់វិធីសាស្ត្រលើកកម្ពស់ និងការអប់រំសុខភាពឲ្យបានសមរម្យសម្រាប់ស្ថានភាព និងគុណតម្លៃរបស់អ្នកជំងឺការជឿជាក់ការប្រតិបត្តិថែទាំសុខភាពកម្រិត នៃ ការលូតលាស់តម្រូវការសិក្សាការត្រៀមខ្លួន និងលទ្ធភាពដើម្បីសិក្សាភាសាដែលចូលចិត្ត ជំនឿសាសនាប្រពៃណីវប្បធម៌ ទំនៀមទម្លាប់និងស្ថានភាពសេដ្ឋកិច្ចសង្គម។
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការទំនាក់ទំនងអំពីការលើកកម្ពស់សុខភាព ការបង្ការជំងឺសម្រាប់អ្នកជំងឺនៅគ្រប់គ្រឹះស្ថានថែទាំសុខភាព។
- ផ្តួចផ្តើមឲ្យមានសម្ព័ន្ធអ្នកប្រើប្រាស់សេវា និងក្រុមអ្នកតស៊ូមតិឲ្យបានសមរម្យក្នុងសកម្មភាពអប់រំនិងលើកកម្ពស់សុខភាព។
- ផ្តល់គោលការណ៍ណែនាំស្តីពីការចូលរួមដល់បុគ្គលក្រុមគ្រួសារក្រុម និងសហគមន៍ដើម្បីលើកកម្ពស់សុខភាពនិងការបង្ការ កាត់បន្ថយបញ្ហាសុខភាពឬកែប្រែឥរិយាបថដែលប្រឈមនឹងគ្រោះថ្នាក់។

*គ.__បរិញ្ញាបត្រគិលានុបដ្ឋាក__*

បន្ថែមពីលើភារកិច្ចរបស់បរិញ្ញាបត្ររងគិលានុបដ្ឋាក***__បរិញ្ញាបត្រគិលានុបដ្ឋាកត្រូវ៖__***

- ស្វែងរកឱកាសក្នុងការផ្តល់ព័ត៌មានត្រឡប់ និង ការវាយតម្លៃអំពីប្រសិទ្ធភាពនៃយុទ្ធសាស្រ្ត ដែលបានអនុវត្ត។
- រៀបចំប្រព័ន្ធព័ត៌មានសុខាភិបាល និងអប់រំអំពីការថែទាំសុខភាពដល់អ្នកប្រើប្រាស់សេវា ឲ្យបានសមរម្យអំពីតម្រូវការលូតលាស់របស់អ្នកជំងឺ ការត្រៀមខ្លួន និងលទ្ធភាពដើម្បី សិក្សាតម្លៃនៃវប្បធម៌និងជំនឿសាសនា។
- វាយតម្លៃអំពីប្រភពប្រព័ន្ធព័ត៌មានសុខាភិបាលដូចជាអ៊ីនធឺណែតភាពត្រឹមត្រូវនៃតំបន់អនុវត្ត ភាពជឿជាក់ និងការយល់ឃើញដែលជួយឲ្យអ្នកជំងឺប្រើប្រាស់ប្រព័ន្ធព័ត៌មានសុខាភិបាល ឲ្យមានគុណភាព៕